# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា
## ថ្លែងក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៤
## " ឈានទៅរក  គ្មានការចម្លងថ្មី  គ្មានការរើសអើង និងគ្មានការស្លាប់ "
## ដោយផ្តោតទៅលើ "ការយកចិត្តទុកដាក់រួមគ្នា ដើម្បីសម្រេច
## ឱ្យបានភាពគ្មានមេរោគអេដស៍សម្រាប់ប្រជាជនជំនាន់ក្រោយ"


ដោយឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី

និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

និងជាប្រធានគណៈកម្មាធិការសម្របសម្រួលកម្មវិធីមូលនិធិសកលប្រចាំប្រទេស


សាលមហោស្រពចតុមុខ

ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤

សុន្ទរកថា

ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ក្នុង **ទិវាអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ** ឈានទៅរក

"**គ្មានការចម្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់**" ដោយផ្តោតទៅលើ

"***ការយកចិត្តទុកដាក់ ធ្វើជាដៃគូ ធ្វើឱ្យសម្រេច ៖ ជំនាន់ដែលគ្មានមេរោគអេដស៍***"

សាលមហោស្រពចតុមុខ ថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ
- សូមគោរពគណៈអធិបតី
- សូមគោរព ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ថ្នាក់ដឹកនាំ តំណាងស្ថាប័ន ក្រសួងនៃរាជរដ្ឋាភិបាលកម្ពុជា
- សូមគោរពឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត នៃបណ្តាលប្រទេសនានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- សូមស្វាគមន៍ លោក លោកស្រី អ្នកនាងកញ្ញា ជាតំណាងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល តំណាង អ្នកផ្ទុកមេរោគអេដស៍ និង តំណាងប្រជាជនគោលដៅ ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីគោរពរាប់អាន
- សូមស្វាគមន៍ចំពោះប្អូនៗ ក្មួយៗនិស្សិត និងតំណាងយុវជនកាកបាទក្រហមទាំងអស់ដែលមានវត្តមាននាឱកាសដ៏មហោឡារិកនេះ

ថ្ងៃនេះក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្នុងនាមខ្លួនខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំព្រះករុណាខ្ញុំសូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និង ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីនាពេលនេះ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍លើកទី២២ នៅកម្ពុជានាឆ្នាំនេះបានរៀបចំឡើងនៅថ្ងៃទី២៧ ខែវិច្ឆិកា ដែលខុសពីសព្វមួយដង គឺពីមុនយើងធ្លាប់ប្រារព្វនៅរៀងរាល់ថ្ងៃទី១ធ្នូ ។ ការផ្លាស់ប្តូរនេះក្នុងគោលបំណងបង្កើនការចូលរួមពេញលេញពីគ្រប់ដៃគូទាំងអស់ និងមិនជាន់ជាមួយកម្មវិធីសំខាន់ៗផ្សេងៗទៀត ។ ចូលរួមក្នុងការរៀបចំការប្រារព្វទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសហការជាមួយដៃគូ និងសង្គមស៊ីវិលក្នុងការរៀបចំសកម្មភាពមួយចំនួនរួមមាន ៖

១) ការប្រារព្វទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ដែលយើងរៀបចំ នៅក្នុងថ្ងៃនេះ ដោយមានអ្នកចូលរួមទាំងអស់ប្រមាណជា៧០០នាក់ ។

២) ការរៀបចំកិច្ចប្រជុំតុមូល ដែលដឹកនាំរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ អង្គការខាន់ណា (KHANA) អង្គការ HACC តំណាងអ្នកផ្ទុកមេរោគអេដស៍ តំណាងក្រុមប្រជាជនគោលដៅ និងតំណាងអង្គការសង្គមស៊ីវិល ក្រោមប្រធានបទ "គ្មានការចម្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់ ដោយសារមេរោគអេដស៍ និង ជំងឺអេដស៍" ។ កិច្ចប្រជុំតុមូលនេះបានប្រព្រឹត្តទៅនៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា ។

៣) ការចុះអប់រំផ្ទាល់ដែលដឹកនាំរៀបចំដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានកិច្ចសហការជាមួយអង្គការ HACC ដោយប្រើប្រាស់ល្បែងសំណួរ-ចម្លើយ ការចែកចាយឯកសារផ្សព្វផ្សាយ អាវយឺត ស្រោមអនាម័យ និង ការផ្សព្វផ្សាយតាមរយៈសារនៅលើបដា រួមនឹងការប្រគំតន្ត្រីជាសាធារណៈផងដែរ ។

៤) ការរៀបចំជាឆាកកំប្លែងអប់រំដោយអង្គការសង្គមស៊ីវិល ក្នុងគោលបំណងអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងកាន់តែច្បាស់ពីការឆ្លងមេរោគអេដស៍ និង ការបង្ការ

ការឆ្លងដោយមានប្រសិទ្ធភាព ។ ឆាកកំប្លែងនេះនឹងធ្វើការចាក់ផ្សាយនៅក្នុងស្ថានីយ៍ទូរទស្សន៍ CTN និង MyTV ផងដែរ ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ការរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូនេះ គឺ ក្នុងគោលបំណងបង្កើនការចូលរួមការឆ្លើយតបទូលំទូលាយ និង ពហុវិស័យទៅនឹងការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ បង្កើនការអប់រំដើម្បីធ្វើយ៉ាងណាសម្រេចបាននូវគោលដៅសូន្យ-បីៈ គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការស្លាប់ និង គ្មានការរើសអើង ជាពិសេសការចូលរួមរបស់យុវជនក្នុងការពង្រឹងសីលធម៌សង្គម ការយល់ដឹងនូវសុខភាពបន្តពូជ និង សកម្មភាពផ្លូវភេទ ដើម្បីទប់ស្កាត់ និង បង្ការការឆ្លងមេរោគអេដស៍ថ្មី និង ជាជនបង្គោលក្នុងការជួយអប់រំមិត្តភក្តិនៅក្នុងសាលា និង ក្រៅសាលា ។ ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ នេះ គឺផ្តល់ឱកាសឱ្យយើងទាំងអស់គ្នាទទួលស្គាល់ថា នៅលើសកលលោកនេះពិតជាកំពុងតែមានការរីករាលដាលមេរោគអេដស៍ដ៏គ្រោះថ្នាក់ ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

នៅក្នុងឱកាសនេះខ្ញុំព្រះករុណា-ខ្ញុំ សូមជម្រាបជូនថា នៅប្រទេសកម្ពុជាអាត្រាផ្ទុកមេរោគអេដស៍កំពុងតែមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ យោងតាមការព្យាករណ៍តាមបែបវិទ្យាសាស្ត្របានបង្ហាញឱ្យដឹងថា នៅត្រឹមឆ្នាំ២០១៤នេះ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យ ដែលមានអាយុពី១៥ ដល់ ៤៩ឆ្នាំ គឺមាន ០.៤% ដែលបន្តធ្លាក់ចុះពី ០.៦% នៅឆ្នាំ២០១៣ ។ គិតមកត្រឹមឆ្នាំ២០១៤នេះ កម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៣,៧៣៣នាក់ ក្នុងនោះស្ត្រីដែលផ្ទុកមេរោគអេដស៍មានចំនួន៣៩,៥១៦នាក់ ដែលជាចំនួនមួយលើសចំនួនបុរសដែលផ្ទុកមេរោគអេដស៍ ។ យោងតាមការព្យាករណ៍ថ្មីៗនេះរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ចំនួនអ្នកផ្ទុកមេរោគអេដស៍នឹងបន្តធ្លាក់ចុះទៅដល់ ៧០,៤០០នាក់ នៅត្រឹមឆ្នាំ២០១៥ ដែលក្នុងនោះករណីឆ្លងថ្មីគឺមានត្រឹមតែប្រមាណជាបី (០៣) នាក់ក្នុងមួយថ្ងៃ ។ ចំពោះកុមារផ្ទុកមេរោគអេដស៍ គឺមានចំនួនប្រមាណជា៨,៥១២នាក់ នៅឆ្នាំ២០១០ និង បន្តធ្លាក់ចុះបន្តិចម្តងៗមកនៅត្រឹមតែ ៥,៤៩៧នាក់

នៅត្រឹមឆ្នាំ២០១៥ ។ រីឯការថែទាំ និង ព្យាបាលអ្នកផ្ទុកមេរោគអេដស៍វិញ គឺនៅត្រឹមតែ ប្រាំបួន (០៩) ខែដើមឆ្នាំ២០១៤នេះ មានអ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ចំនួន ៥១,៧៨៣ នាក់ ដែលទទួលបានការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ក្នុងនោះស្ត្រីមានចំនួន ២៧ ,៧៨៥នាក់ និង កុមារអាយុតិចជាង១៥ឆ្នាំ មានចំនួន៣,៩០២នាក់ (ក្នុងនោះកុមារីមានចំនួន១,៨៣៥នាក់) ។ ឆ្លងតាមព័ត៌មានស្តីពីស្ថានភាពរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ដែលបានរៀបរាប់កន្លងមកនេះ យើងអាចសន្និដ្ឋានបានថា កម្ពុជាជាប្រទេសមួយមានលទ្ធភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យការរាលដាលមេរោគអេដស៍ ប្រកបដោយជោគជ័យ និង ប្រកបដោយក្តីសង្ឃឹមថាអត្រាឆ្លងមេរោគអេដស៍ថ្មីនឹងធ្លាក់ចុះជាបន្តទៀតនៅឆ្នាំខាងមុខ។

ជាមួយគ្នានេះដែរការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក៏មានការថយចុះគួរឱ្យកត់សម្គាល់គឺបានធ្លាក់ចុះពី១៣% នៅក្នុងឆ្នាំ២០១០ មកត្រឹម ២%នៅក្នុងឆ្នាំ២០១៤ ។ នេះគឺជាក្តីសង្ឃឹមមួយទៀតប្រកបដោយការជឿជាក់ថា កម្ពុជានឹងអាចចូលរួមជាមួយពិភពលោកក្នុងការកាត់បន្ថយទាំងស្រុងនូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅត្រឹមឆ្នាំ២០២០ខាងមុខនេះ។

ប្រការដែលយើងត្រូវអបអរសាទរផងដែរនោះគឺ អត្រាផ្ទុកមេរោគអេដស៍បានធ្លាក់ចុះជាបន្តបន្ទាប់ក្នុងចំណោមនារីបម្រើសេវាតាមគ្រឹះស្ថានកម្សាន្តសប្បាយ ដែលមានអត្រាត្រឹមតែ ០.៩%ប៉ុណ្ណោះ យោងតាមតួលេខដែលទើបនឹងទទួលបានក្នុងពេលថ្មីៗនេះ ។ បើប្រៀបធៀបអត្រានេះជាមួយនឹងប្រទេសជិតខាង យើងអាចសន្និដ្ឋានបានថាប្រទេសកម្ពុជាកំពុងឈានមុខគេក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ តាមរយៈការចុះ ពិនិត្យសភាពការណ៍ជាក់ស្តែង នៅតាមខេត្តនាខែកន្លងមក ខ្ញុំព្រះករុណាខ្ញុំសង្កេតឃើញមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់មន្ត្រីសុខាភិបាល និង អង្គការសង្គមស៊ីវិលក្នុងការជំរុញសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ។ ហើយអ្នកដែលបានមកធ្វើតេស្តឈាមដោយស្ម័គ្រចិត្តទាំងនោះ គឺភាគច្រើនជាយុវវ័យដែលមកពីមជ្ឈដ្ឋានទីទៃៗ មិនមែនមកតែ ពីក្រុមនារីបម្រើសេវាតាមគ្រឹះស្ថានកម្សាន្តសប្បាយនោះទេ ។ ជាមួយការធ្វើតេស្តឈាមរកមេរោគអេដស៍អតិថិជនស្ម័គ្រចិត្តទាំងនោះ ក៏ទទួលផងដែរនូវការណែនាំ ឬដំបូន្មានល្អៗអំពីសុវត្ថិភាពនៃការរួមភេទ ជាពិសេសអំពីផលប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យផងដែរ ។ ជាលទ្ធផលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើស្រោមអនាម័យមានការកើនឡើងគួរឱ្យកត់សម្គាល់ ។ ក្រៅពីការចែកចាយស្រោមអនាម័យដោយឥតគិតថ្លៃពីអង្គការសង្គម ស៊ីវិល ស្រោមអនាម័យក៏អាចរកទិញបាននៅតាមផ្សារទំនើប ស្ថានីយប្រេងឥន្ធនៈ ឬនៅក្បែរសេវាកម្សាន្តសប្បាយ ដោយមិនគិតពីនៅតាមឱសថស្ថានដែលធ្លាប់ដាក់លក់ជាយូរមកហើយនោះ

ទេ ។ ជាមួយគ្នានេះ ឥរិយាបទនៃអ្នកប្រើស្រោមអនាម័យទាំងស្រី ទាំងប្រុស ក៏មានការវិវឌ្ឍន៍ឡើងដែរ ដោយពួកគេភាគច្រើនពុំមានការអៀនខ្មាស់ទៀតឡើយ ។ ចំណែកឯការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ ក៏មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ដែរ ។ ឧទាហរណ៍ អ្នកផ្ទុកមេរោគអេដស៍ណាដែលបានទទួលការឧបត្ថម្ភគាំពារ និង ថែទាំយ៉ាងទៀងទាត់ពីស្ថាប័នរដ្ឋ ឬពីអង្គការសង្គមស៊ីវិលខាងផ្នែកសុខាភិបាល និង ផ្នែកសង្គមកិច្ច ព្រមទាំងបានទទួលជោគជ័យក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ គឺលែងត្រូវគេមាក់ងាយ ឬរើសអើងដូចមុនទៀតហើយ ។ ផ្ទុយទៅវិញពួកគេបានទទួលការរាប់អានដោយស្មើមុខជាមនុស្សធម្មតា ជាក់ស្តែងដូចជាករណីនៅស្រុកបាទី ខេត្តតាកែវ និង នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុជាដើម ។ ក៏ប៉ុន្តែចំពោះអ្នកផ្ទុកមេរោគអេដស៍ ដែលមិនបានទទួលការគាំពារជិតដល់ ដែលមានជីវភាពដុនដាបនៅឡើយ គឺអ្នកទាំងនោះនៅទទួលរងការមាក់ងាយ និង រើសអើងខ្លះៗនៅឡើយ ។

ទាំងនេះគឺជា លទ្ធផលនៃកិច្ចប្រឹងប្រែងរួមគ្នាក្នុងការរៀបចំគោលនយោបាយក្នុងការឆ្លើយតបទូលំ ទូលាយ និង ជាពហុវិស័យ និង ការផ្តល់សេវាព្យាបាល និង ថែទាំជាសកលរបស់អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ និងដៃ គូដែលពាក់ព័ន្ធ ។

ជាងនេះទៅទៀតក៏មានអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ កុមារកំព្រា និង កុមារងាយរងគ្រោះដោយសារជំងឺអេដស៍ប្រមាណជា៧០ភាគរយ តែងតែទទួលបាននូវការគាំទ្រសង្គម សេដ្ឋកិច្ច សុខភាពការអប់រំ។ល។ ជាពិសេស គឺតាមរយៈការងារមនុស្សធម៌ដែលមិនចេះនឿយហត់ និង មិនចេះរីងស្ងួតរបស់កាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និង ជាមគ្គុទេសក៍ដ៏ឆ្នើម ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ។

ជាមួយនឹងសញ្ញាជាវិជ្ជមានខាងលើ យើងក៏មានការ ព្រួយបារម្ភយ៉ាងខ្លាំងចំពោះ **រលកទី២** នៃការរីករាលដាលនៃមេរោគអេដស៍ដែលនឹងអាចកើតមាននៅលើទឹកដីដ៏ពិសិដ្ឋរបស់យើង ។ ការរីករាលដាលសារជាថ្មីនេះអាចកើតឡើង ជាពិសេសក្នុងចំណោមយុវជនយុវតី កម្មករ កម្មការិនី និង ជនចំណាកស្រុក បន្ថែមទៅលើក្រុមគោលដៅចាស់ដែលជាក្រុមនារីបម្រើសេវាកម្សាន្ត ក្រុមបុរសស្រឡាញ់បុរស និង ក្រុមស្រីស្រស់ ។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធព័ត៌មានវិទ្យា ការរស់នៅបែបពពាក់ពពូនគ្នារវាងស្ត្រី និង បុរស យុវជន និងយុវតី ភាពផុយស្រួយនៃរបាំងប្រពៃណីពីបូរមបុរាណ ភាពងាយស្រួលក្នុងការទាក់ទងគ្នា និងក្នុងការរួមភេទ សុទ្ធតែជាកត្តាព្រួយបារម្ភពីរលកទី២នៃការរីករាលដាលមេរោគអេស៍នៅកម្ពុជា។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ការចូលរួមជាមួយពិភពលោក ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ជារៀងរាល់ឆ្នាំកន្លងមកគឺ យើងបានប្រើប្រាស់សាររួមគ្នា ក្នុងគោលបំណងបង្ហាញពីសុឆន្ទៈ ចូលរួមជាមួយពិភពលោក ក្នុងការលើកក ម្ពស់ការយល់ដឹងថ្មីៗពីការរាលដាលមេរោគអេដស៍ និង ចំណេះដឹងវិទ្យាសាស្ត្រ ប្រកបដោយប្រសិទ្ធភាពជូនដល់សាធារណៈជនទូទៅ និង ជាការដាស់ស្មារតីប្រជាពលរដ្ឋឱ្យចងចាំជានិច្ចពីគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍ និង ជំងឺអេដស៍ ។ លើសពីនេះការរៀបចំទិវានេះគឺ មាន គោលបំណងស្វែងរកការគាំទ្របន្ថែមទៀតពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋ ពីគ្រប់មជ្ឈដ្ឋាន ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលទាំងអស់ ក្នុងការចូលរួមវិភាគទានដល់ការទប់ស្កាត់ការរាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និង នៅលើពិភពលោកទាំងមូលក្រោមពាក្យស្លោក "គ្មានការចម្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់ ដោយសារមេរោគអេដស៍ និង ជំងឺអេដស៍" ប្រកបដោយជោគជ័យនៅត្រឹមឆ្នាំ២០២០ ។ ជាងនេះទៀត ដើម្បីសម្រេចបានគោលដៅសូន្យ-បីនេះ សកលលោកបានចូលរួមទាំងអស់គ្នានិងបានបន្ថែម សារមួយទៀតសម្រាប់ទិវាប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំនេះគឺ៖ *"ផ្តោតការយកចិត្តទុកដាក់ ធ្វើជាដៃគូ ធ្វើឱ្យ សម្រេចបាននូវ៖ ជំនាន់ដែលគ្មានមេរោគអេដស៍"* (Focus, Partner, Achieve: An AIDS-Free Generation) ។ សារនេះគឺ ឧបករណ៍មួយសម្រាប់ជំរុញឱ្យយើងទាំងអស់គ្នា បញ្ចប់ការរាលដាលមេរោគអេដស៍នៅលើសកលលោក ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

**Focus** គឺជាការយកចិត្តទុកដាក់ក្នុងការឆ្លើយតបឱ្យចំទៅនឹងនិន្នាការការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ ការរៀបចំយុទ្ធសាស្ត្រឆ្លើយតប និង បទអន្តរាគមន៍ ឱ្យចំគោលដៅ និង ប្រជាជនចំណុច ។ **Partner** គឺការរួមគ្នាជាដៃគូ ដែលមានសារៈសំខាន់ ណាស់ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍។ ដូចឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបមកហើយថា ពុំមានស្ថាប័នណាតែមួយ អាចបញ្ចប់ការរាលមេរោគអេដស៍បានទេ គឺត្រូវតែមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោម ជាតិ។ ពិតប្រាកដណាស់វេជ្ជបណ្ឌិត គិលានុប្បដ្ឋាក អ្នកជំនាញក្នុងការសិក្សា និង ស្រាវជ្រាវ គឺជាមនុស្ស

គន្លឹះសម្រាប់ការគ្រប់គ្រងការរាលដាលមេរោគអេដស៍ ប៉ុន្តែយើងក៏មិនអាចខ្វះ បាននូវការចូលរួមពីសហគមន៍អ្នកផ្ទុកមេរោគអេដស៍ អាជ្ញាធរមូលដ្ឋាន ក្រុមប្រជាជនដែល ប្រឈមមុខខ្ពស់ និង អង្គការសង្គមស៊ីវិលបានទេ ។ **Achieve** គឺជាសមិទ្ធផល ដែលជួយដាស់តឿនយើងទាំងអស់គ្នាឲ្យបញ្ចប់ការរីករាលដាលមេរោគអេដស៍ ។ អ្វីដែលសំខាន់សម្រាប់យើងទាំងអស់គ្នានោះគឺ បន្តការព្យាបាល ថែទាំដល់អ្នកផ្ទុកមេរោគអេដស៍ និង ធ្វើយ៉ាងណាបង្កើនការធ្វើតេស្តឈាមរកមេរោគអេដស៍ និង ធ្វើការបង្ការ និង ការព្យាបាលឱ្យទាន់ពេលវេលា ។ ក្នុងនាមជាអ្នកផ្តល់សេវា អ្នកគ្រប់គ្រងសេវា និង ក្នុងនាមជារដ្ឋអំណាចមូលដ្ឋាន យើងត្រូវបង្កើនការផ្តល់សេវា ដោយពុំមានការរើសអើង និង ប្រកបដោយគុណភាពសម្រាប់អ្នកជំងឺ និង អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ឱ្យកាន់តែមានភាពប្រសើរឡើង ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ដើម្បីឈានទៅសម្រេចបាននូវយុទ្ធសាស្ត្រសូន្យ-បី និង ចូលរួមអនុវត្តន៍នូវសារខាងលើនេះ តាងនាមឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង រូបខ្ញុំព្រះករុណាខ្ញុំផ្ទាល់ យើងនឹងខិតខំសម្រប សម្រួល និង ដឹកនាំបន្ថែមទៀតក្នុងការឆ្លើយតបឆ្ពោះទៅកាន់ភាពជោគជ័យ ដែលមានដូច ខាងក្រោម ៖

១) ធានាថាការរៀបចំផែនការការវិនិយោគ និង ការអនុវត្តន៍សកម្មភាពត្រូវបានរៀបចំឡើងដោយឈរលើទិន្នន័យមានភស្តុតាង ជាគោលអាង យកសិទ្ធិមនុស្សជាមូលដ្ឋាន និង យកលទ្ធផលជាគោលដៅតម្រង់ទិស។

២) ការជំរុញដំណោះស្រាយដែលធានាប្រសិទ្ធភាពក្នុងការងារវិស័យអេដស៍ និង ក្នុងវិស័យសុខាភិបាល និង ទាមទារការវិនិយោគខ្ពស់ក្នុងវិស័យទាំងពីរ ។ ការងារនេះត្រូវធ្វើឡើងដោយឈរលើជោគជ័យកន្លងទៅ និង ដោយដាក់បញ្ចូលដំណោះស្រាយលើចំណុចខ្វះខាតបច្ចុប្បន្ន។

៣) ជំរុញការខិតខំប្រឹងប្រែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ក្រសួងនានាដែលជាសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ធ្វើឱ្យការអភិវឌ្ឍន៍នានាកាន់តែទទួលបានជោគជ័យ និង ប្រសិទ្ធភាព ។

៤) រចនាសម្ព័ន្ធឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍គប្បីត្រូវកសាងនៅលើជោគជ័យដែលមានស្រាប់ និង ត្រូវបានតម្រង់ទិសជុំវិញអភិក្រមដែលផ្តោតលើ

មនុស្ស និង សុខុមាលភាពរបស់ពួកគេជាជាងផ្តោតតែលើជំងឺអេដស៍ដែលមាន វិធីសាស្ត្រជំងឺជាក់លាក់មួយដែល ជំរុញសកម្មភាពពហុវិស័យសមាហរណកម្ម ការច្នៃប្រឌិត និង វិធីសាស្ត្រដើម្បីជួយដល់ភាគីពាក់ព័ន្ធលើកដំណោះស្រាយ សុខភាព និង ការអភិវឌ្ឍន៍រួមបញ្ចូលទាំងសិទ្ធិជាមូលដ្ឋានផងដែរ។

៥) លើកទឹកចិត្តឱ្យមានពហុភាពនៃការចូលរួមពីស្ថាប័ននានា ដែលអាចកែប្រែកត្តាកំណត់សុខភាពរួមទាំងបរិយាកាសអំណោយផល និង ស៊ីណែកហ្ស៊ីរវាងវិស័យអភិវឌ្ឍន៍មួយចំនួន ។

ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណា-ខ្ញុំ សូមជូននូវសារបន្ថែមមួយចំនួនទៀត ជូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីរួមគ្នាបន្ថែមទៀតប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម៖

១) សូមប្រជាពលរដ្ឋទាំងអស់ មេត្តាស្វែងយល់ឱ្យបានជាប្រចាំ នូវចំណេះដឹងថ្មីៗ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ ដើម្បីប្រើប្រាស់ ការពារខ្លួនយើង គ្រួសារយើង និង សង្គមជាតិយើងពីគ្រោះថ្នាក់នៃមេរោគអេដស៍ ។

២) បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អតិថិជនទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវការប្រើប្រាស់ស្រោមអនាម័យជាប្រចាំឱ្យបាន១០០ភាគរយ។

៣) បុរសកម្ពុជាទាំងអស់ត្រូវចូលរួមយ៉ាងសកម្មក្នុងការទទួលខុសត្រូវ ចំពោះខ្លួនឯងផ្ទាល់ ប្រពន្ធ និង កូនចៅរបស់ខ្លួនពីការចម្លងមេរោគអេដស៍ ដោយប្រកាន់ខ្ជាប់នូវការប្រព្រឹត្តប្រកបដោយសុវត្ថិភាព និង ការទទួលខុសត្រូវ ។ ប្រសិនបើសង្ស័យថាបានប្រព្រឹត្តមិនគប្បី សូមទៅធ្វើតេស្តឈាម ដើម្បីជួយបង្ការការឆ្លងមេរោគអេដស៍។

៤) ក្មួយៗយុវវ័យទាំងអស់ មិនត្រូវឆាប់ប្រឡូកនឹងការរួមភេទនោះទេ ហើយត្រូវចាកចេញឱ្យឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន ដែលជាប្រភពគ្រោះថ្នាក់ខ្ពស់នៃការចម្លងមេរោគអេដស៍ ។

៥) ស្ត្រីមានផ្ទៃពោះទាំងអស់រួមជាមួយស្វាមី ត្រូវស្វែងរកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានទាន់ពេលវេលា។

៦) យើងទាំងអស់គ្នា ត្រូវចូលរួមលុបបំបាត់ ការរើសអើង និងមាក់ងាយ ដល់អ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ឱ្យបានជាដាច់ខាត ។

៧) អ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ទាំងអស់ ត្រូវស្វែងរកការថែទាំ និងព្យាបាលឱ្យបានឆាប់ ព្រមទាំងគោរពវេជ្ជបញ្ជាឱ្យបានខ្ជាប់ខ្ជួន ដើម្បីចៀសវាងឱ្យ

បាននូវ ភាពស៊ាំរបស់មេរោគអេដស៍ ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ដែលអាចកើតឡើងដែលជាមូលហេតុធ្ងន់ធ្ងរនៃមរណភាពដោយសារជំងឺអេដស៍ ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ទន្ទឹមនឹងភាពជោគជ័យក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍នេះ ប្រទេសកម្ពុជាក៏ប្រឈមនឹងការកាត់បន្ថយថវិកាសម្រាប់ប្រើប្រាស់ ដើម្បីបន្តការឆ្លើយតបការបង្ការ និងការព្យាបាល ថែទាំអ្នកផ្ទុកមេរោគអេដស៍នៅឆ្នាំបន្តបន្ទាប់ខាងមុខនេះ ។ ក្រោមការ សម្របសម្រួល និង ដឹកនាំដោយគណៈកម្មាធិការសម្របសម្រួលនៃមូលនិធិសកលប្រចាំ ប្រទេសដែលមានខ្ញុំព្រះករុណាខ្ញុំជាប្រធាន និង ដោយមានជំនួយការបច្ចេកទេសនៃក្រុមការងារស្នូលរបស់កម្មវិធីអេដស៍ បានធ្វើការសម្របសម្រួល រៀបចំឯកសារបង្ហាញទស្សនៈ ដើម្បីលើកគម្រោងថវិកាមូលនិធិសកលសម្រាប់កម្មវិធីអេដស៍ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដោយមានការចូលរួមពីគ្រប់ភាគីទាំងអស់ ។ ឯកសារបង្ហាញទស្សនៈនេះរៀបចំឡើងដោយឈរលើយុទ្ធសាស្ត្រថ្នាក់ជាតិដែលមានស្រាប់ ក្នុងបរិបទមួយដែលថវិកាមូលនិធិសកលមានការថយចុះ និង ជ្រើសយកអាទិភាពនៃកិច្ចអន្តរាគមន៍ដែលមានផលសម្រេចកម្រិតខ្ពស់ជាមួយប្រជាជនគន្លឹះដែលទទួលរងផលប៉ះពាល់ និង ការជ្រើសរើសទីតាំងភូមិសាស្ត្រជាអាទិភាព ។ ឯកសារនេះនឹងរៀបចំចប់សព្វគ្រប់ និង ស្នើទៅមូលនិធិសកលនៅពាក់កណ្តាលខែមករា ឆ្នាំ២០១៥ ខាងមុខនេះ ។

ជាមួយគ្នានេះដែរ ឆ្លើយតបទៅនឹង តម្រូវការរៀបចំឯកសារបង្ហាញទស្សនៈនេះ ដែលទាមទារឱ្យមានថវិកាបដិភាគពីរដ្ឋាភិបាលផងនោះ តាមការផ្តល់ដំណឹងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុថា រាជរដ្ឋាភិបាលនឹងចូលរួមជាមួយមូលនិធិសកល ដោយប្រើថវិកាជាតិចំនួន ១លានដុល្លារសម្រាប់ឆ្នាំ២០១៥ ចំនួន១,២លានដុល្លារ សម្រាប់ឆ្នាំ២០១៦ និង ចំនួន ១,៥លានដុល្លារ សម្រាប់ឆ្នាំ២០១៧ ដើម្បីទិញថ្នាំព្យាបាលអ្នកជំងឺអេដស៍ ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ក្នុងឱកាសនេះដែរ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង រូបខ្ញុំព្រះករុណាខ្ញុំផ្ទាល់តាមរយៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំស្នើសុំស្ថាប័នរដ្ឋទាំងឡាយ បន្តគាំទ្រគោលនយោបាយប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានរឹងរឹតតែសកម្មថែមទៀត ដើម្បីសម្រេចបានជោគជ័យជាស្ថាពរទៅលើជំងឺអេដស៍ ។

ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងអស់បន្តជួយ និង បង្កើនការគាំទ្រហិរញ្ញវត្ថុ ការគាំទ្រគោលនយោបាយ និង បទអន្តរាគមន៍គន្លឹះបន្ថែមទៀត ដើម្បីឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានលទ្ធភាពពង្រីកអត្រាគ្របដណ្តប់ទៅលើភូមិសាស្ត្រ ក្រុមគោលដៅ និង សេវាបន្ថែមទៀត និង ប្រកបដោយចីរភាព ឈានទៅស ម្រេចបាននូវគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ និង គោលដៅសូន្យ-បី នាឆ្នាំ២០២០ខាងមុខ ។

*ព្រះថេរានុថេរៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព!*

ជាទីបញ្ចប់ ខ្ញុំ ព្រះករុណាខ្ញុំសូមប្រសិទ្ធពរប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជូនគណៈអធិបតី ជាពិសេស ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម លោកជំទាវ លោក -លោកស្រី កងកម្លាំង ប្រដាប់អាវុធ ព្រមទាំងក្មួយៗសិស្សានុសិស្ស ទាំងអស់ នូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និង សូមសម្តែងនូវការកោតសរសើរផងចំពោះ សមាជិក-សមាជិកាទាំងអស់នៃគណៈកម្មការរៀបចំអង្គពិធី ដែលបានខិតខំប្រឹងប្រែងចូលរួម រៀបចំពិធីដ៏មានសារៈសំខាន់នាពេលនេះឱ្យប្រកប ដោយជោគជ័យ ។

*សូមអរគុណ!*